សំណើ

# 2 បង្កើនមូលនិធិបម្រុងទុកសម្រាប់គ្រាអាសន្នរបស់រដ្ឋ។ វិសោធនកម្មរដ្ឋធម្មនុញ្ញនីតិបញ្ញត្តិ។

2

**ចំណងជើងផ្លូវការ និងសេចក្ដីសង្ខេប** រៀបចំដោយអគ្គរដ្ឋអាជ្ញា

**អត្ថបទនៅក្នុងវិធានការនេះអាចរកបាននៅទំព័រ 106 និងគេហទំព័ររដ្ឋលេខាធិការតាមរយៈ *voterguide.sos.ca.gov*។**

- បង្កើនមូលនិធិបម្រុងទុកសម្រាប់គ្រាអាសន្នរបស់រដ្ឋ California ដែលត្រូវបានអនុម័តដោយអ្នកបោះឆ្នោតក្នុងឆ្នាំ 2014 ដើម្បីផ្ដល់ហិរញ្ញប្បទានសម្រាប់ការអប់រំ ការថែទាំសុខភាព សុវត្ថិភាព សាធារណៈ និងសេវាសំខាន់ៗផ្សេងទៀតក្នុងអំឡុងពេលសេដ្ឋកិច្ចធ្លាក់ចុះ។
- ដំឡើងកម្រិតនៃថវិកាបម្រុងទ្វេដងពី 10% ទៅ 20% នៃប្រាក់ចំណូលមូលនិធិទូទៅ ដោយតម្រូវឱ្យមានការសន្សំរហូតទាល់តែសមតុល្យរបស់មូលនិធិស្មើនឹង 20% នៃមូលនិធិទូទៅ។
- តម្រូវឱ្យមានការសន្សំបន្ថែមនៅក្នុងឆ្នាំណាដែលមានចំណូលលើពន្ធមានអត្រាខ្ពស់។
- បង្កើនថវិកាបម្រុងដែលមានស្រាប់សម្រាប់ការអប់រំ បំណុលរដ្ឋ និងកាតព្វកិច្ចប្រាក់សោធននិវត្តន៍។

**សេចក្ដីសង្ខេបនៃការប៉ាន់ប្រមាណរបស់អ្នកវិភាគនីតិបញ្ញត្តិអំពីផលប៉ះពាល់សារពើពន្ធរបស់រដ្ឋាភិបាលមូលដ្ឋាន និងរដ្ឋ៖**

- កម្រិតថវិកាបម្រុងរបស់រដ្ឋនឹងខ្ពស់ជាងមុន។

ការបោះឆ្នោតចុងក្រោយដោយស្ថាប័ននីតិបញ្ញត្តិលើ ACA 20 (សំណើ 2)
(ជំពូក 130, លក្ខន្តិកៈនៃឆ្នាំ 2026)

| | | |
|---|---|---|
| ព្រឹទ្ធសភា៖ | ការបោះឆ្នោតគាំទ្រ 29 | បោះឆ្នោតប្រឆាំង 2 |
| សភា៖ | បោះឆ្នោតគាំទ្រ 59 | បោះឆ្នោតប្រឆាំង 8 |

**ការវិភាគដោយ អ្នកវិភាគច្បាប់**

## សាវតារ

### ថវិការដ្ឋ

***តើរដ្ឋចំណាយប្រាក់របស់ខ្លួនយ៉ាងដូចម្ដេច?*** នៅឆ្នាំនេះ រដ្ឋមានគម្រោងចំណាយប្រហែល $250 ពាន់លានពីមូលនិធិទូទៅ ដើម្បីទូទាត់សម្រាប់សេវាកម្មដល់សាធារណជន។ មូលនិធិទូទៅគឺជាគណនីដែលរដ្ឋប្រើប្រាស់ដើម្បីចំណាយសម្រាប់សេវាកម្មសាធារណៈភាគច្រើន។ ប្រហែលពាក់កណ្ដាលនៃការចំណាយនេះគឺសម្រាប់សាលារៀន មហាវិទ្យាល័យសហគមន៍ និងសាកលវិទ្យាល័យសាធារណៈរបស់រដ្ឋ។ (រដ្ឋធម្មនុញ្ញរបស់រដ្ឋកំណត់កម្រិតនៃការចំណាយអប្បបរមាសម្រាប់សាលារៀន និងមហាវិទ្យាល័យសហគមន៍។) ប្រហែលមួយភាគបីនៃការចំណាយរបស់រដ្ឋគឺសម្រាប់កម្មវិធីសុខភាពនិងសេវាកម្មមនុស្ស ដែលភាគច្រើនសម្រាប់កម្មវិធីធានារ៉ាប់រងសុខភាពអ្នកមានចំណូលទាបរបស់រដ្ឋ គឺ Medi-Cal។ ចំណែកដែលនៅសល់ភាគច្រើនទៅលើពន្ធនាគារ តុលាការ និងសេវាកម្មរដ្ឋផ្សេងៗទៀត។

***តើរដ្ឋប្រមូលប្រាក់ចំណូលយ៉ាងដូចម្ដេច?*** ពន្ធលើប្រាក់ចំណូលគឺជាពន្ធដ៏ធំបំផុតរបស់រដ្ឋ។ វាទូទាត់សម្រាប់ការចំណាយភាគច្រើនពីមូលនិធិទូទៅ។ ពន្ធសំខាន់ៗផ្សេងទៀតរួមមាន ពន្ធសាជីវកម្ម និងពន្ធលើការលក់។ ពន្ធលើប្រាក់ចំណូលភាគច្រើនត្រូវបានបង់ដោយអ្នកបង់ពន្ធដែលមានចំណូលខ្ពស់ ដែលប្រាក់ចំណូលរបស់ពួកគេជារឿយៗរួមបញ្ចូលប្រាក់ចំណេញពីភាគហ៊ុន និងការវិនិយោគផ្សេងៗទៀត។

***ប្រាក់ចំណូលរបស់រដ្ឋមិនអាចទាយទុកជាមុនបានទេ។*** ប្រាក់ចំណូលរបស់រដ្ឋឡើងចុះខ្លាំងពីមួយឆ្នាំទៅមួយឆ្នាំ។ នេះដោយសារតែប្រាក់ចំណូល

អាស្រ័យទៅលើដំណើរការនៃសេដ្ឋកិច្ច និង ទីផ្សារភាគហ៊ុន។ នៅពេលដែលអ្វីៗដំណើរការល្អ ប្រាក់ចំណូលអាចកើនឡើងយ៉ាងឆាប់រហ័ស។ នៅពេលដែលអ្វីៗដំណើរការមិនល្អ ដូចជានៅអំឡុងពេលវិបត្តិសេដ្ឋកិច្ច ឬការដួលរលំនៃទីផ្សារភាគហ៊ុន ប្រាក់ចំណូលអាចធ្លាក់ចុះរាប់សិបពាន់លានដុល្លារ។ ក្នុងអំឡុងពេលវិបត្តិសេដ្ឋកិច្ចធ្ងន់ធ្ងរ ឬការដួលរលំទីផ្សារ ការធ្លាក់ចុះប្រាក់ចំណូលសរុបក្នុងរយៈពេលពីរបីឆ្នាំអាចស្មើនឹង 50% ឬច្រើនជាងនេះនៃប្រាក់ចំណូលមូលនិធិទូទៅប្រចាំឆ្នាំ។

***រដ្ឋត្រូវតែបំពេញតាមតម្រូវការថវិកាជាក់លាក់ជារៀងរាល់ឆ្នាំ។*** រដ្ឋធម្មនុញ្ញរបស់រដ្ឋតម្រូវឱ្យស្ថាប័ននីតិបញ្ញត្តិអនុម័តថវិកាដែលមានតុល្យភាពជារៀងរាល់ឆ្នាំ។ នេះមានន័យថារដ្ឋមិនអាចអនុម័តថវិកាដែលចំណាយប្រាក់ច្រើនជាងប្រាក់ដែលមានស្រាប់នោះទេ។ លើសពីនេះ រដ្ឋធម្មនុញ្ញរបស់រដ្ឋកំណត់ទំហំប្រាក់ចំណូលពន្ធដែលរដ្ឋអាចចំណាយបាន។ ដែនកំណត់នេះត្រូវបានហៅថា "ដែនកំណត់នៃការចាត់ចែងរបស់រដ្ឋ"។ ការចំណាយមួយចំនួន—ដូចជាហេដ្ឋារចនាសម្ព័ន្ធ—មិនរាប់បញ្ចូលក្នុងដែនកំណត់នោះទេ។ ការចំណាយផ្សេងទៀតទាំងអស់ រួមទាំងប្រាក់ដែលដាក់ទៅក្នុងទុនបម្រុង គឺត្រូវបានរាប់បញ្ចូលក្នុងដែនកំណត់នោះ។

## ទុនបម្រុង

***ទុនបម្រុងអនុញ្ញាតឱ្យរដ្ឋរក្សាការចំណាយនៅពេលដែលប្រាក់ចំណូលធ្លាក់ចុះ។*** រដ្ឋដាក់ប្រាក់ទៅក្នុងទុនបម្រុងនៅពេលដែលសេដ្ឋកិច្ចដំណើរការល្អ។ នេះមានន័យថាប្រាក់ត្រូវបានសន្សំជំនួសឱ្យការចំណាយលើកម្មវិធីសាធារណៈក្នុងអំឡុងពេលទាំងនេះ។ នៅពេលដែលសេដ្ឋកិច្ចកាន់តែអាក្រក់ ហើយប្រាក់ចំណូលធ្លាក់ចុះ រដ្ឋប្រើប្រាស់ទុនបម្រុងដើម្បីជួយរក្សាការចំណាយលើកម្មវិធីសាធារណៈ។ ទុនបម្រុងជួយឱ្យរដ្ឋចៀសវាងការកាត់បន្ថយការចំណាយមួយចំនួន ការដំឡើងពន្ធ និងការខ្ចីប្រាក់ដើម្បីធ្វើឱ្យថវិកាមានតុល្យភាព។ បច្ចុប្បន្ន រដ្ឋមានទុនបម្រុងប្រហែល $20 ពាន់លានដែលអាចប្រើប្រាស់សម្រាប់កម្មវិធីសាធារណៈណាមួយ។

***រដ្ឋធម្មនុញ្ញរបស់រដ្ឋតម្រូវឱ្យរដ្ឋសន្សំប្រាក់នៅក្នុង «មូលនិធិបម្រុងសម្រាប់គ្រាអាសន្ន»។*** រដ្ឋធម្មនុញ្ញរបស់រដ្ឋតម្រូវឱ្យរដ្ឋដាក់ប្រាក់ 0.75% នៃប្រាក់ចំណូលពន្ធនៃមូលនិធិទូទៅទៅក្នុងមូលនិធិបម្រុងសម្រាប់គ្រាអាសន្នចម្បងរបស់រដ្ឋ ដែលត្រូវបានហៅថា គណនីស្ថិរភាពថវិកា ជារៀងរាល់ឆ្នាំ។ ប្រាក់នៅក្នុងមូលនិធិបម្រុងសម្រាប់គ្រាអាសន្នអាចត្រូវបានប្រើប្រាស់សម្រាប់កម្មវិធីរដ្ឋណាមួយ។ លើសពីនេះ រដ្ឋត្រូវតែដាក់ប្រាក់បន្ថែមទៀតទៅក្នុងមូលនិធិបម្រុងសម្រាប់គ្រាអាសន្នក្នុងប៉ុន្មានឆ្នាំដែលប្រាក់ចំណូលពីពន្ធលើប្រាក់ចំណេញពីការវិនិយោគខ្ពស់ជាងធម្មតា។ ក្នុងអំឡុងពេលមានអាសន្នថវិកា រដ្ឋអាចបញ្ឈប់ការដាក់ប្រាក់ និង/ឬដកប្រាក់ចេញពីមូលនិធិបម្រុងសម្រាប់គ្រាអាសន្ន។

***ការសន្សំមិនត្រូវបានទាមទារទៀតទេ នៅពេលដែលមូលនិធិបម្រុងសម្រាប់គ្រាអាសន្នឈានដល់កម្រិតជាក់លាក់មួយ។*** នៅពេលដែលប្រាក់នៅក្នុងមូលនិធិបម្រុងសម្រាប់គ្រាអាសន្នឈានដល់ 10% នៃពន្ធនៃមូលនិធិទូទៅ រដ្ឋលែងតម្រូវឱ្យធ្វើការដាក់ប្រាក់បន្ថែមទៀតហើយ។ ប្រាក់ដែលគួរតែបានចូលទៅក្នុងមូលនិធិបម្រុងសម្រាប់គ្រាអាសន្ន ជំនួសវិញត្រូវតែចំណាយលើហេដ្ឋារចនាសម្ព័ន្ធ (ដូចជាផ្លូវហាយវេ និងលំនៅឋាន)។

## បំណុល

***រដ្ឋមានបំណុលប្រភេទផ្សេងៗគ្នា។*** រដ្ឋមានបំណុលជាង $250 ពាន់លាន។ ទាំងនេះរួមមានបំណុលសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ និងសោធននិវត្តន៍ និង

អត្ថប្រយោជន៍សុខភាពអ្នកចូលនិវត្តន៍ដែលរកបានដោយបុគ្គលិករដ្ឋ។ ជួនកាលរដ្ឋក៏ខ្ចីប្រាក់ពីមូលនិធិរដ្ឋផ្សេងទៀត ដើម្បីជួយទូទាត់ការចំណាយនៃមូលនិធិទូទៅផងដែរ។ បំណុលរបស់រដ្ឋត្រូវបានសងវិញតាមពេលវេលា ជាទូទៅយោងទៅតាមកាលវិភាគ ឬផែនការ។ ជារៀងរាល់ឆ្នាំ រដ្ឋធ្វើការទូទាត់បំណុលរបស់ខ្លួន។

***រដ្ឋធម្មនុញ្ញរបស់រដ្ឋតម្រូវឱ្យរដ្ឋធ្វើការទូទាត់បំណុលបន្ថែមឆ្ពោះទៅរកសោធននិវត្តន៍ និងអត្ថប្រយោជន៍សុខភាព។*** រដ្ឋធម្មនុញ្ញរបស់រដ្ឋតម្រូវឱ្យរដ្ឋធ្វើការទូទាត់បំណុលបន្ថែមលើសពីអ្វីដែលជាធម្មតាបានធ្វើជារៀងរាល់ឆ្នាំ។ ចំនួនទឹកប្រាក់នៃការទូទាត់បំណុលបន្ថែមទាំងនេះ គឺដូចគ្នានឹងចំនួនទឹកប្រាក់ដែលបានដាក់ចូលទៅក្នុងមូលនិធិបម្រុងសម្រាប់គ្រាអាសន្នជារៀងរាល់ឆ្នាំដំបូងឡើយ។ រដ្ឋអាចប្រើប្រាស់ការទូទាត់បំណុលបន្ថែមទាំងនេះត្រឹមតែដើម្បីទូទាត់បំណុលសោធននិវត្តន៍រយៈពេលវែង និងបំណុលថែទាំសុខភាពអ្នកចូលនិវត្តន៍ប៉ុណ្ណោះ។ ការធ្វើការទូទាត់បន្ថែមឆ្ពោះទៅរកបំណុលទាំងនេះ ជួយសន្សំប្រាក់រដ្ឋក្នុងរយៈពេលវែង។

***ការទូទាត់បំណុលបន្ថែមជាជម្រើសក្រោយឆ្នាំ 2030។*** តម្រូវការសម្រាប់ការទូទាត់បំណុលបន្ថែមបញ្ចប់នៅឆ្នាំ 2030។ បន្ទាប់ពីនោះ ស្ថាប័ននីតិបញ្ញត្តិ និងអភិបាលរដ្ឋអាចសម្រេចចិត្តដាក់ប្រាក់សម្រាប់ការទូទាត់បំណុលបន្ថែមចូលទៅក្នុងមូលនិធិបម្រុងសម្រាប់គ្រាអាសន្នជំនួសវិញ។ ឬក៏ ស្ថាប័ននីតិបញ្ញត្តិ និងអភិបាលរដ្ឋអាចធ្វើការទូទាត់បំណុលបន្ថែមក្នុងចំនួនតិចតួចជាងមុន ហើយដាក់ប្រាក់ដែលនៅសល់ចូលទៅក្នុងមូលនិធិបម្រុងសម្រាប់គ្រាអាសន្ន។

## សំណើ

***សន្សំបន្ថែមនៅក្នុងមូលនិធិបម្រុងសម្រាប់គ្រាអាសន្ន។*** សំណើ 2 តម្រូវឱ្យរដ្ឋធ្វើការដាក់ប្រាក់ចូលទៅក្នុងមូលនិធិបម្រុងសម្រាប់គ្រាអាសន្នរហូតដល់វាឈានដល់ 20% នៃពន្ធនៃមូលនិធិទូទៅ (ជំនួសឱ្យ 10% នៃពន្ធនៃមូលនិធិទូទៅ)។ លើសពីនេះ រដ្ឋនឹងធ្វើការដាក់ប្រាក់សូម្បីតែធំជាងនេះនៅក្នុងប៉ុន្មានឆ្នាំដែលប្រាក់ចំណូលពីពន្ធលើប្រាក់ចំណេញពីការវិនិយោគមានកម្រិតខ្ពស់ខ្លាំង ដូចជានៅពេលដែលទីផ្សារភាគហ៊ុនកំពុងរីកចម្រើន។

***បន្ត និងពង្រីកការទូទាត់បំណុលបន្ថែម។*** សំណើ 2 ក៏តម្រូវឱ្យរដ្ឋធ្វើការទូទាត់បំណុលបន្ថែមរហូតដល់ឆ្នាំ 2040 (ជំនួសឱ្យត្រឹមឆ្នាំ 2030) ផងដែរ។ ការទូទាត់បំណុលទាំងនេះនឹងមានចំនួនដូចគ្នានឹងចំនួនទឹកប្រាក់ដែលបានដាក់ចូលទៅក្នុងមូលនិធិបម្រុងសម្រាប់គ្រាអាសន្នជារៀងរាល់ឆ្នាំដំបូងឡើយ។ លើសពីនេះ ចំនួនទឹកប្រាក់ដែលបានទុកឡែកសម្រាប់ការទូទាត់បំណុលបន្ថែម អាចត្រូវបានប្រើប្រាស់សម្រាប់គោលបំណងដែលបានពង្រីកបន្ថែមមួយចំនួន។ ជាពិសេស ការទូទាត់ទាំងនេះអាចត្រូវបានប្រើប្រាស់ដើម្បីធ្វើការទូទាត់ដែលត្រូវការចាំបាច់ដល់សាលារៀន និងមហាវិទ្យាល័យសហគមន៍ សងប្រាក់កម្ចីពីមូលនិធិរដ្ឋផ្សេងទៀត និងសងប្រាក់កម្ចីជាក់លាក់ពីរដ្ឋាភិបាលសហព័ន្ធ។

***ផ្លាស់ប្តូររបៀបដែលការដាក់ប្រាក់នៃមូលនិធិបម្រុងសម្រាប់គ្រាអាសន្នរាប់បញ្ចូលទៅក្នុងដែនកំណត់នៃការចាត់ចែងរបស់រដ្ឋ។*** ការដាក់ប្រាក់ចូលទៅក្នុងមូលនិធិបម្រុងសម្រាប់គ្រាអាសន្ន នឹងមិនរាប់បញ្ចូលក្នុងដែនកំណត់នៃការចាត់ចែងរបស់រដ្ឋទេ។ ផ្ទុយទៅវិញ ប្រាក់នេះនឹងត្រូវបានរាប់បញ្ចូលក្នុងដែនកំណត់នោះនៅពេលដែលវាត្រូវបានដកចេញ។

ការវិភាគដោយ អ្នកវិភាគច្បាប់

បន្ត

***ផ្លាស់ប្តូររបៀបដែលការដាក់ប្រាក់ផ្សេងទៀតរាប់បញ្ចូលទៅក្នុងដែនកំណត់នៃការចាត់ចែងរបស់រដ្ឋ។*** រដ្ឋមានគណនីមួយដើម្បីទុកមូលនិធិឡែកនៅពេលដែលប្រាក់ចំណូលកំពុងកើនឡើងខ្លាំង។ តាមរយៈការទុកមូលនិធិទាំងនេះឡែក រដ្ឋអាចចៀសវាងការចំណាយលើសនៅពេលដែលការប៉ាន់ស្មានប្រាក់ចំណូលគឺមិនប្រាកដប្រជាជាពិសេស។ ក្រោមសំណើ 2 ការដាក់ប្រាក់ចូលទៅក្នុងគណនីនេះក៏នឹងមិនរាប់បញ្ចូលក្នុងដែនកំណត់នៃការចាត់ចែងរបស់រដ្ឋផងដែរ។ ផ្ទុយទៅវិញ ប្រាក់នេះនឹងត្រូវបានរាប់បញ្ចូលក្នុងដែនកំណត់នោះនៅពេលដែលវាត្រូវបានដកចេញ។ ការមិនរាប់បញ្ចូលនេះមិនអាចមានទំហំធំជាង 10% នៃពន្ធនៃមូលនិធិទូទៅក្នុងឆ្នាំនីមួយៗនោះទេ។

## ផលប៉ះពាល់សារពើពន្ធ

***កម្រិតថវិកាបម្រុងរបស់រដ្ឋនឹងខ្ពស់ជាងមុន។*** តាមរយៈការបន្តតម្រូវឱ្យមានការដាក់ប្រាក់ចូលទៅក្នុងមូលនិធិបម្រុងសម្រាប់គ្រាអាសន្ន រហូតដល់សមតុល្យឈានដល់ 20% នៃពន្ធនៃមូលនិធិទូទៅ រដ្ឋនឹងសន្សំបានកាន់តែច្រើនតាមពេលវេលា។ លើសពីនេះ តាមរយៈការដាក់ប្រាក់កាន់តែច្រើននៅពេលដែលប្រាក់ចំណូលកំពុងកើនឡើងខ្លាំង រដ្ឋទំនងជានឹងសន្សំបានកាន់តែច្រើននៅក្នុងមូលនិធិបម្រុងសម្រាប់គ្រាអាសន្នក្នុងរយៈពេលប៉ុន្មានឆ្នាំជាក់លាក់ណាមួយ។ ទុនបម្រុងកាន់តែច្រើននឹងធ្វើឱ្យការធ្វើឱ្យថវិកាមានតុល្យភាពកាន់តែងាយស្រួលខ្លះៗនៅពេលដែលប្រាក់ចំណូលធ្លាក់ចុះ។

***អាចមានការទូទាត់បំណុលកាន់តែច្រើន។*** តាមរយៈការតម្រូវឱ្យរដ្ឋធ្វើការទូទាត់បំណុលបន្ថែមរហូតដល់ឆ្នាំ 2040 រដ្ឋអាចនឹងធ្វើការទូទាត់បំណុលកាន់តែច្រើនជាងមុនប្រសិនបើគ្មានសំណើ 2។

**សូមចូលទៅកាន់ *sos.ca.gov/campaign-lobbying/cal-access-resources/measure-contributions/2026-ballot-measure-contribution-totals* សម្រាប់បញ្ជី គណៈកម្មាធិការបង្កើតឡើងជាចម្បងដើម្បីគាំទ្រ ឬប្រឆាំងវិធានការនេះ។**

**សូមចូលទៅកាន់ *fppc.ca.gov/transparency/top-contributors.html* ដើម្បីចូលមើលអ្នកជួយវិភាគទានកំពូលទាំង 10 របស់គណៈកម្មាធិការ។**